ធ៧-០២-៤៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការរក្សាប្រាក់បម្រុងកាតព្វកិច្ចចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណត្រូវតម្កល់ប្រាក់បម្រុងកាតព្វកិច្ចចំនួន ៥ ភាគរយ (៥%) នៃប្រាក់បញ្ញើអតិថិជនរបស់ខ្លួនក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។

**ប្រការ ២**.-

ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់បញ្ញើដែលមាននៅក្នុងតារាងតុល្យការរបស់គ្រឹះស្ថាន និងក្នុងរបាយការណ៍បែងចែកប្រភេទប្រាក់បញ្ញើដែលគ្រឹះស្ថានប្រមូលបាននៅចុងខែនីមួយៗ។ ការគណនាប្រាក់បម្រុងកាតព្វកិច្ចត្រូវដកចេញប្រាក់សន្សំកាតព្វកិច្ចដែលជាលក្ខខណ្ឌក្នុងការផ្តល់ឥណទាន។

**ប្រការ ៣**.-

ប្រាក់បម្រុងកាតព្វកិច្ចដូចក្នុងប្រការ២ ដែលបានគណនានៅខែណាមួយ ត្រូវរក្សាទុកក្នុងគណនីរបស់គ្រឹះស្ថាននៅធនាគារជាតិនៃកម្ពុជា ចាប់ពីថ្ងៃទី១៥ នៃខែបន្ទាប់រហូតដល់ថ្ងៃទី១៤ នៃខែបន្ទាប់ទៀតហើយការគណនានិងរក្សាទុកប្រាក់បម្រុងកាតព្វកិច្ចត្រូវអនុវត្តដូចគ្នានេះជាបន្តបន្ទាប់តាមគ្រានីមួយៗ។

**ប្រការ ៤**.-

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានឱនភាពប្រាក់បម្រុងកាតព្វកិច្ចត្រូវបំពេញជាបន្ទាន់នៅពេលណាដែលគ្រឹះស្ថានទាំងនេះទទួលបានសេចក្តីជូនដំណឹងពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៥**.-

គ្រឹះស្ថានណាដែលមិនគោរពតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**